ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងព្រហ្មទណ្ឌលេខ: ២១៤៧ អ.ក
ចុះថ្ងៃទី២៨-ធ្នូ-២០២១
សាលក្រមលេខ: ១១០ (ន)
ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង០៩ព្រឹក ដោយមានសមាសភាពដូចតទៅ÷

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ២១៤៧ អ.ក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ដែលមានជនជាប់ចោទ÷ ឈ្មោះ [redacted] សំអឿន ភេទប្រុស អាយុ៣៥ឆ្នាំ (កើតឆ្នាំ១៩៨៦) សញ្ជាតិខ្មែរ មុខរបរកម្មកររោងចក្រ កម្រិតវប្បធម៌ថ្នាក់ទី០៥ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិតាពេជ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះ អ៊ុន(ស្លាប់) ម្តាយឈ្មោះ [redacted] អៀង(រស់) ប្រពន្ធឈ្មោះ [redacted] ស្រីណុប មានកូនចំនួន០១នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ឃុំខ្លួនថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២)

-ជាប់ចោទពីបទ: ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិតាពេជ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] ការិយាល័យមេធាវី អិល ជេ អាសយដ្ឋានផ្ទះលេខ២៦៣ ផ្លូវព្រះត្រសក់ផ្អែម (៦៣) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉ុម ភេទប្រុស អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិតាពេជ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៦៨៤ ដកសព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាដំណោះស្រាយលេខ: ៧១១ ដកដស ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ: ៧៦៨ ដកចត/២២ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។


Scanned with CamScanner

## អង្គហេតុមានដូចតទៅ

-កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង១៨ និង៤០នាទីល្ងាច មានករណី ប៉ុនប៉ងឃាតកម្ម កើតឡើង នៅភូមិតាពេជ ឃុំឈ្មាំង ស្រុកពាញាឮ ខេត្តកណ្ដាល ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] សំអឿន បានជួបជុំគ្នាជាមួយជនរងគ្រោះក្នុងកម្មវិធីបង្កក់កូនរបស់ជនសង្ស័យ ខណៈពេលកំពុងផឹកស៊ីជាមួយគ្នា ជនសង្ស័យក៏បានទាស់ពាក្យសំដីជាមួយឈ្មោះ [redacted] មករា ដែលជាប្រពន្ធជនរងគ្រោះឈ្មោះ [redacted] សារ៉ុម អាយុ៣៥ឆ្នាំ ហើយជនសង្ស័យបានគប់កែវស្រាចូលទៅក្នុងវង់ផឹកស៊ី ភ្លាមនោះជនរងគ្រោះខឹងបានស្ទុះទៅបម្រុងវាយជនសង្ស័យ ប៉ុន្តែត្រូវបានបងប្អូនជួយឃាត់ និងបំបែកចេញ។ មួយសន្ទុះក្រោយមកជនសង្ស័យក៏បានដើរចេញពីក្នុងផ្ទះ ត្រឡប់មកកន្លែងផឹកស៊ីវិញ ដោយនៅក្នុងដៃមានកាន់កាំបិតប៉ុងតោចំនួន០២ ព្រមទាំងបបួលជនរងគ្រោះកាប់គ្នាមួយស្មើ និយាយរួចជនសង្ស័យបានបោះកាំបិតចំនួន០១ឱ្យទៅជនរងគ្រោះ តែបណ្ដាលឱ្យត្រូវជើងរបស់ប្រពន្ធជនរងគ្រោះ ឃើញដូចនេះជនរងគ្រោះមានចិត្តខឹងយ៉ាងខ្លាំង ហើយបានទាញយកដំបងឈើបម្រុងវាយជនសង្ស័យ តែត្រូវបានជនសង្ស័យយកកាំបិតប៉ុងតោ ដែលកាន់នៅនឹងដៃស្រាប់កាប់មកលើក្បាលជនរងគ្រោះ០១កាំបិត តែជនរងគ្រោះគេច ត្រូវចិញ្ចើមខាងឆ្វេងរយៈដាច់សាច់ ហូរឈាមស្រោចពេញដី នឹងត្រូវដៃខាងស្ដាំរបស់ជនរងគ្រោះ បណ្ដាលឱ្យជនរងគ្រោះដួលសន្លប់ទៅលើដី។ ភ្លាមៗក៏មានបងប្អូនដែលចូលរួមកម្មវិធីជួយឃាត់ បំបែកចេញ និងនាំជនរងគ្រោះទៅព្យាបាលនៅមន្ទីរពេទ្យ ក្រោយមកសមត្ថកិច្ចទទួលបានពាក្យបណ្ដឹងពីបងប្រុសជនរងគ្រោះភ្លាម សមត្ថកិច្ចក៏បានចុះមកឃាត់ខ្លួនជនសង្ស័យ រួមទាំងវត្ថុតាងបញ្ជូនមកអធិការដ្ឋាននគរបាលស្រុកពញាឮ ដើម្បីចាត់ការតែម្ដង។

## ពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សំអឿន បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃកើតហេតុក្នុងកម្មវិធីខួបកំណើតកូនរបស់ខ្លួន ខ្លួនពិតជាបានទាស់ពាក្យសម្ដីជាមួយជនរងគ្រោះ និងប្រពន្ធជនរងគ្រោះ។ ជនរងគ្រោះឈ្មោះ [redacted] សារ៉ុម ត្រូវជាបងថ្លៃខ្លួន ពេលទាស់សម្ដីគ្នានោះ ជនរងគ្រោះបានស្ទុះមកវាយខ្លួន តែត្រូវបានបងប្អូនបំបែកចេញ។ ក្រោយមកខ្លួននៅមានចិត្តខឹងក៏ដើរចូលទៅក្នុងផ្ទះបំណាងយកកាំបិតប៉ុងតោចំនួន០២មកកាប់គ្នាជាមួយជនរងគ្រោះ ដោយបោះកាំបិតមួយទៅឱ្យជនរងគ្រោះ និងកាំបិតមួយទៀតខ្លួនកាន់ជាប់នឹងដៃ ហើយភ្លាមនោះខ្លួនបានកាប់ទៅលើក្បាលរបស់ជនរងគ្រោះចំនួន០១កាំបិត តែជនរងគ្រោះគេចចេញត្រូវចំចិញ្ចើមខាងឆ្វេង នឹងត្រូវចំកដៃខាងស្ដាំ បណ្ដាលឱ្យជនរងគ្រោះរងរបួសហូរឈាម និងដួលសន្លប់។

-ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉ុម បានឆ្លើយបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] សំអឿន ត្រូវជាប្អូនថ្លៃរបស់ខ្លួន ហើយមិនធ្លាប់មានទំនាស់ជាមួយគ្នាពីមុននោះទេ នៅចុងខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង០៧យប់ មានកម្មវិធីបង្កក់កូនរបស់ជនជាប់ចោទ។ ជនជាប់ចោទមានសភាពស្រវឹងខ្លាំង ហើយមានទំនាស់ជាមួយប្រពន្ធខ្លួន និងបានយកកែវគប់ចូលទៅក្នុងវង់ផឹកស៊ី ភ្លាមនោះខ្លួនបានខឹងស្ទុះទៅបម្រុងវាយជនសង្ស័យ ប៉ុន្តែត្រូវបានបងប្អូនជួយឃាត់ និងបំបែកចេញ។ បន្ទាប់មក ជនជាប់ចោទបានយកកាំបិតកាប់មកលើខ្លួនចំនួន០១កាំបិត ត្រូវចិញ្ចើមខាងឆ្វេងរយៈដាច់សាច់ ហូរឈាមស្រោចពេញដី បណ្ដាលឱ្យខ្លួនដួលសន្លប់ទៅលើដី។ ចំពោះការព្យាបាលរបួសខ្លួនបានចំណាយអស់ ១០០០$។ ខ្លួនសូមទាមទារសំណងថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តចំនួន ២០លានរៀល។

-សាក្សីឈ្មោះ [redacted] ឧត្តម មានតួនាទីជា អនុប្រធានការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ បានឆ្លើយបញ្ជាក់ថាៈ ចំពោះរឿងនេះខ្លួនពុំបានដឹងនោះទេ ព្រោះសំណុំរឿងនេះខាងអធិការដ្ឋាននគរបាលស្រុកពញាឮ ជាអ្នករៀបចំកសាងបញ្ជូនមក ខ្លួនមានតួនាទីគ្រាន់តែបញ្ជូនបន្តមកកាន់អយ្យការអមសាលាដំបូងខេត្តកណ្ដាល តែប៉ុណ្ណោះ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សារុន បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង១៨ និង៤០នាទី ខ្លួន និងបងប្រុស បានចូលរួមកម្មវិធីបង្កក់កូនរបស់ប្អូនឈ្មោះ [redacted] សំអឿន រួចក៏បានផឹកស៊ី ជួបជុំបងប្អូនជាធម្មតា។ លុះក្រោយមកឈ្មោះ [redacted] សំអឿន បានស្រវឹងហើយបាននិយាយច្រើនពីបញ្ហាក្នុងគ្រួសាររបស់គាត់ ដោយពាក្យសម្ដីដៀមដាមមិនសមរម្យ ទៅលើឈ្មោះ [redacted] មករា ដែលត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted]សារ៉ុម។ ភ្លាមនោះស្រាប់តែឈ្មោះ [redacted] មករា បានឆ្លើយថា “មិនបាច់មកចេះប្រដៅក្រុមគ្រួសារអញនោះទេ មើលតែប្រពន្ធកូនខ្លួនឯងឱ្យតែល្អទៅ” ដោយឮសម្ដីដូចនេះឈ្មោះ[redacted]សំអឿន បានខឹងច្រលោតបោកកែវ បោកចាន នៅលើតុផឹកស៊ី ឃើញសភាពដូចនោះពួកខ្លួនបានឃាត់ និងសម្រួលគ្នាទាំងសងខាង ដោយឱ្យប្អូនថ្លៃឈ្មោះ[redacted] សំអឿន ចូលទៅក្នុងផ្ទះ រួចខ្លួនក៏មកនិយាយគ្នាលេងជាមួយឈ្មោះ [redacted] សារ៉ុម ត្រូវជាបងបង្កើតនៅខាងមុខផ្ទះ។ ភ្លាមនោះស្រាប់តែឈ្មោះ [redacted]សំអឿន ដើរចេញពីក្នុងផ្ទះមកវិញ ដោយបានកាន់កាំបិតប៉ុងតោពណ៌ស ចំនួនពីរ មកគប់ទៅលើឈ្មោះ ឆាយ សារ៉ុម តែពុំត្រូវបែរទៅត្រូវជើងប្រពន្ធរបស់គាត់ទៅវិញ ធ្វើឱ្យប្ដីគាត់ខឹងក៏យកដំបងបម្រុងវាយទៅលើឈ្មោះ[redacted] សំអឿន តែក៏ត្រូវឈ្មោះ[redacted] សំអឿន នោះមកកាប់ទៅលើបងប្រុសខ្លួនមួយប៉ុងតោ បណ្ដាលរងរបួសក្បាលមួយផ្នែកនៅលើចិញ្ចើមខាងស្ដាំ និងដៃខាងស្ដាំ ដោយឃើញសភាពបងប្រុសខ្លួនរបួសធ្ងន់ ក៏នាំគ្នាយកទៅពេទ្យនៅភ្នំពេញ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted]ពេជ្រ បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ ខ្លួនបានធ្វើដំណើរមកចូលរួមក្នុងពិធីបង្កក់កូនប្អូនថ្លៃឈ្មោះ [redacted] សំអឿន ស្ថិតនៅភូមិតាពេជ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល ក្រោយពីធ្វើពិធីចប់សព្វគ្រប់គឺនៅវេលាម៉ោង០១រសៀល ថ្ងៃដដែល ក៏បានជួបជុំបងប្អូននាំគ្នាផឹកស៊ីសប្បាយនៅកន្លែងកម្មវិធីនោះ។ លុះដល់វេលាម៉ោង០៦ល្ងាច ថ្ងៃដដែល ស្រាប់តែឈ្មោះ [redacted] សំអឿន បានទាស់ពាក្យសម្ដីគ្នាជាមួយឈ្មោះ [redacted] មករា ភេទស្រី ពេលនោះឈ្មោះ [redacted] មករា បាននិយាយទៅកាន់ឈ្មោះ[redacted] សំអឿន ថា “កុំចេះរឿងគ្រួសារអញ គិតតែគ្រួសារឯងទៅ” ភ្លាមនោះឈ្មោះ [redacted] សំអឿន ក៏បានយកកែវបោកទៅគ្រែកន្លែងផឹកស៊ី ឃើញដូច្នេះឈ្មោះ [redacted] សារ៉ុម ដែលត្រូវជាប្ដីឈ្មោះ [redacted] មករា ស្ទុះទៅវាយឈ្មោះ[redacted] សំអឿន ប៉ុន្តែត្រូវបងប្អូនឃាត់ជាប់ ចំណែកឈ្មោះ [redacted] សំអឿន ក៏ចូលទៅក្នុងផ្ទះរបស់ខ្លួនទៅយកកាំបិតប៉ុងតោរកកាប់ ប៉ុន្តែត្រូវបានបងប្អូនឃាត់ជាប់ ហើយក៏ស្ងប់ស្ងាត់ទៅ។ រហូតមកដល់វេលាម៉ោង០៧យប់ ថ្ងៃដដែល ខ្លួនបាននាំគ្នាអង្គុយផឹកស៊ីបន្ត ស្រាប់តែឈ្មោះ [redacted] សំអឿន បានដើរចេញពីក្នុងផ្ទះកាន់កាំបិតប៉ុងតោ ចំនួនពីរ ដើរចូលមកកន្លែងខ្លួនផឹកស៊ី ហើយឈ្មោះ [redacted] សំអឿន បានបោះកាំបិតប៉ុងតោចំនួនមួយមកពួកខ្លួន បណ្ដាលឱ្យត្រូវជើងរបស់ឈ្មោះ [redacted] មករា ឃើញដូច្នេះឈ្មោះ [redacted] សារ៉ុម ដែលត្រូវជាប្ដី ស្ទុះទៅយកដំបងឈើមូល បម្រុងវាយឈ្មោះ[redacted] សំអឿន តែត្រូវឈ្មោះ[redacted] សំអឿន យកកាំបិតប៉ុងតោមួយទៀត ស្ទុះទៅកាប់ឈ្មោះ [redacted] សារ៉ុម លើផ្នែកក្បាលចំលើចិញ្ចើមខាងស្ដាំ និងប្រអប់ដៃខាងស្ដាំរងរបួសធ្ងន់ធ្ងរ ហើយត្រូវបានក្រុមគ្រួសារយកទៅព្យាបាលនៅមន្ទីរពេទ្យភ្នំពេញ ចំណែកឈ្មោះ [redacted] សំអឿន ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

-អំណានចម្លើយសាក្សីឈ្មោះ[redacted] នេន បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១៨ និង៤០នាទី ខ្លួនបានទៅចូលរួមកម្មវិធីបង្កក់កូន ប្អូនជីមួយ ស្ថិតនៅភូមិតាពេជ ឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្តាល រួចក៏បានជួបជុំផឹកស៊ី ជាមួយបងប្អូនជាមួយឈ្មោះ[redacted] សំអឿន និងឈ្មោះ[redacted] សារ៉ុម នឹងសាច់ញាតិជាច្រើនទៀត។ ដោយក្នុងកម្មវិធីនោះឈ្មោះ[redacted] សំអឿន ជាម្ចាស់កម្មវិធី បានស្រវឹងយ៉ាងខ្លាំង និយាយរករឿងជៀមដាមទៅលើក្រុមគ្រួសារឈ្មោះ[redacted] សារ៉ុម និងធ្វើសកម្មភាពបោកកែវ បោកចាន នៅលើតុផឹកស៊ី ឃើញមិនស្រួលខ្លួនបានឃាត់ ឱ្យបំបែកចេញរៀងៗខ្លួន។ មួយសន្ទុះក្រោយមក ក៏ឃើញឈ្មោះ[redacted] សំអឿន ដើរចេញពីក្នុងផ្ទះកាន់កាំបិតប៉័ងតោចំនួនពីរ មកកាប់លើឈ្មោះ[redacted] សារ៉ុម តែពុំត្រូវទេ ដោយត្រូវប្រពន្ធរបស់គាត់ចុំជើង។ បន្ទាប់មកឈ្មោះ[redacted] សំអឿន ស្រែកបបួលឈ្មោះ[redacted] សារ៉ុម កាប់គ្នាមួយស្មើ ពេលនិយាយរួចឈ្មោះ[redacted] សំអឿន ស្ទុះទៅកាប់លើឈ្មោះ[redacted] សារ៉ុម តែម្តង បណ្តាលឱ្យត្រូវរបួសក្បាល និងដៃ រួចមកខ្លួននិងបងប្អូន យកគាត់ទៅមន្ទីរពេទ្យភ្នំពេញ។

-ក្រឡាបញ្ជីអានឯកសារនានានៅក្នុងសំណុំរឿងនេះ។

## សិទ្ធិនិយាយស្តីរបស់គាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

-ជនជាប់ចោទឈ្មោះ[redacted] សំអឿន បានកត់សម្គាល់ថា: ខ្ញុំស្នើសុំឱ្យតុលាការប្តូរបទចោទប្រកាន់ ពីបទ: ប៉ុនប៉ងឃាតកម្ម មកបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំ ឆាប់បានចេញជួយរកស៊ីចិញ្ចឹមប្រពន្ធកូនខ្ញុំ។ ព្រោះខ្ញុំគ្មានចេតនាសម្លាប់បងថ្លៃខ្ញុំទេ។

-តំណាងអយ្យការបានសន្និដ្ឋានថា: សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ: ៦៨៤ ដកសព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ទុកជាការបានដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] សំអឿន បានសន្និដ្ឋានថា: ទំនាស់កើតមាននៅក្នុងកម្មវិធីកូនក្តីខ្លួន ជនរងគ្រោះមកតាមវាយកូនក្តីខ្លួនចំនួនបីលើក ទើបកូនក្តីខ្លួនខឹងបានយកកាំបិតចំនួនពីរដើម និងបោះទៅឱ្យជនរងគ្រោះចំនួនមួយដើម។ អំពើនេះគ្រាន់តែជាការប្រព្រឹត្តអំពើហិង្សាទៅវិញទៅមក ដោយសារអ្នកទាំងពីរស្រវឹងរៀងខ្លួន ជនរងគ្រោះបានយកដំបងបម្រុងវាយកូនក្តីខ្លួន ហើយកូនក្តីខ្លួនបានខឹងបានយកកាំបិតកាប់ ប៉ុន្តែគ្មានបំណងក្នុងការសម្លាប់ជនរងគ្រោះនោះទេ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះប្តូរបទចោទពីបទ: ប៉ុនប៉ងឃាតកម្ម តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មកបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

## ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] សំអឿន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សារ៉ុម។

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ[redacted] ឧត្តម។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ[redacted] សារុន, ឈ្មោះ[redacted] ពេជ្រ និងឈ្មោះ[redacted] នេន។

-ក្រោយពីបានស្តាប់ការអានឯកសារនានា។

-ក្រោយពីបានពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] សំអឿន។

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់។



Scanned with CamScanner

## សំអាងហេតុ

## តុលាការយល់ឃើញថា

១- កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១៨ និង៤០នាទី មានករណី ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស បង្កឡើងដោយឈ្មោះ [redacted] សំអឿន ប្រព្រឹត្តនៅភូមិតាពេជ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ពិតប្រាកដមែន។

២- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សំអឿន បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃកើតហេតុក្នុងកម្មវិធីខួបកំណើតកូនរបស់ខ្លួន ខ្លួនពិតជាបានទាស់ពាក្យសម្តីជាមួយជនរងគ្រោះ និងប្រពន្ធជនរងគ្រោះ។ ជនរងគ្រោះឈ្មោះ [redacted] សារ៉ុម ត្រូវជាបងថ្លៃខ្លួន ពេលទាស់សម្តីគ្នានោះ ជនរងគ្រោះបានស្ទុះមកវាយខ្លួន តែត្រូវបានបងប្អូនបំបែកចេញ។ ក្រោយមកខ្លួននៅមានចិត្តខឹងក៏ដើរចូលទៅក្នុងផ្ទះបំណងយកកាំបិតប៉ុងតោចំនួន០២មកកាប់គ្នាជាមួយជនរងគ្រោះ ដោយបោះកាំបិតមួយទៅឱ្យជនរងគ្រោះ និងកាំបិតមួយទៀតខ្លួនកាន់ជាប់នឹងដៃ ហើយភ្លាមនោះខ្លួនបានកាប់ទៅលើក្បាលរបស់ជនរងគ្រោះចំនួន០១កាំបិត តែជនរងគ្រោះគេចចេញត្រូវចិចិញ្ចើមខាងឆ្វេង នឹងត្រូវចំកដៃខាងស្តាំ បណ្តាលឱ្យជនរងគ្រោះរងរបួសហូរឈាម និងដួលសន្លប់។ ចម្លើយសារភាពនេះមានលក្ខណៈស៊ីចង្វាក់ទៅនឹងចម្លើយជនជាប់ចោទនៅគ្រប់ដំណាក់កាលនីតិវិធី ស៊ីចង្វាក់ទៅនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស៊ីចង្វាក់ទៅនឹងចម្លើយសាក្សី និងស៊ីចង្វាក់ទៅនឹងឯកសារគតិយុត្តនានាដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] សំអឿន ពិតជាបានយកកាំបិតកាប់ទៅជនរងគ្រោះឈ្មោះ [redacted] សារ៉ុម ត្រូវចិចិញ្ចើមខាងឆ្វេងរយៈដាច់សាច់ នឹងត្រូវដៃខាងស្តាំហូរឈាម បណ្តាលឱ្យជនរងគ្រោះដួលសន្លប់ទៅលើដី ដោយសារជនជាប់ចោទស្រវឹងស្រា និងខឹងជនរងគ្រោះស្ទុះមកវាយជនជាប់ចោទ។

៣- តាមរបាយការសរុបលេខ: ០៧១ របក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពញាឮ បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] សំអឿន ពិតជាបានយកកាំបិតទៅកាប់ជនរងគ្រោះត្រូវចំចិញ្ចើមខាងឆ្វេង និងកដៃខាងស្តាំ បណ្តាលឱ្យរងរបួស ដែលអំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺជាអំពើហិង្សាដោយចេតនា ប្រាកដមែន។

៤- តាមកំណត់ហេតុទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ រួមមាន: កាំបិតប៉ុងតោធ្វើពីអ៊ីណុកផងឈើ ចំនួនពីរ របស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន។

៥- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន ពិតជាមានចេតនាទុច្ចរិត បានធ្វើសកម្មភាពយកកាំបិតប៉ុងតោកាប់ទៅលើជនរងគ្រោះបណ្តាលឱ្យរងរបួស គឺជាបទល្មើសព្រហ្មទណ្ឌបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

៦- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ: តម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ: ៦៨៤ ដកសព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ការបានដដែល និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិចារណាចំពោះការប្តឹងសុំនេះ។

៧- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សំអឿន បានធ្វើសេចក្តីសន្និដ្ឋានថា: ទំនាស់កើតមាននៅក្នុងកម្មវិធីកូនក្តីខ្លួន ជនរងគ្រោះមកតាមវាយកូនក្តីខ្លួនចំនួនបីលើក ទើបកូនក្តីខ្លួនខឹងបានយកកាំបិតចំនួនពីរដើម និងបោះទៅឱ្យជនរងគ្រោះចំនួនមួយដើម។ អំពើនេះគ្រាន់តែជាការប្រព្រឹត្តអំពើហិង្សាទៅវិញទៅមកដោយសារអ្នកទាំងពីរស្រវឹងរៀងខ្លួន ជនរងគ្រោះបានយកដំបងបម្រុងវាយកូនក្តីខ្លួន ហើយកូនក្តីខ្លួនបានខឹងបានយកកាំបិតកាប់ ប៉ុន្តែគ្មានបំណងក្នុងការសម្លាប់ជនរងគ្រោះនោះទេ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះប្តូរបទចោទពីបទ: ប៉ុនប៉ងឃាតកម្ម តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មកបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិចារណាចំពោះការប្តឹងសុំនេះ។ na



Scanned with CamScanner

៨- ជនជាប់ចោទឈ្មោះ [redacted] សំអឿន ជានីតិជន មានសមត្ថភាព និងស្មារតីគ្រប់គ្រាន់អាចទទួលខុសត្រូវអំពើប្រព្រឹត្តរបស់ខ្លួន។

៩- តាមដីកាដំណោះស្រាយលេខៈ ៧១១ ដកដស ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សំអឿន ទៅតុលាការជំនុំជម្រះពីបទៈ ប៉ុនប៉ងឃាតកម្ម តាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។ ក្រោយពីការសាកសួរដេញដោលពេលសវនាការ និងពិនិត្យភស្តុតាងក្នុងសំណុំរឿង ឃើញថាអំពើប្រព្រឹត្តរបស់ជនជាប់ចោទ ពុំមានធាតុផ្សំគ្រប់គ្រាន់ពីបទៈ ប៉ុនប៉ងឃាតកម្ម អំពើនេះមានធាតុផ្សំគ្រប់គ្រាន់ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស។ ដូច្នេះគប្បីតុលាការសម្រេចកែប្រែបទចោទប្រកាន់ លើជនជាប់ចោទឈ្មោះ [redacted] សំអឿន ពីបទៈ ប៉ុនប៉ងឃាតកម្ម តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មកបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២១៨ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

១០- ក្រោយពីបានពិនិត្យ នឹងពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើ÷ ឈ្មោះ [redacted] សំអឿន ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិតាពេជ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

១១- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន បានធ្វើឱ្យជនរងគ្រោះរងរបួស ប៉ះពាល់ដល់សុខភាពអ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ។

១២- វត្ថុតាង÷ កាំបិតប៉ុងតោចំនួន០២ដង និងដំបងឈើមូលពណ៌ក្រហមចំនួន០១ គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

១៣- ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉ុម បានទាមទារការខូចខាត និងជម្ងឺចិត្តជាទឹកប្រាក់ចំនួន ២០,០០០,០០០ (ម្ភៃលាន)រៀល ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី មិនមានភស្តុតាងជាឯកសារចំណាយថ្លៃព្យាបាលជម្ងឺដាក់ជូនតុលាការពិនិត្យ ដូច្នេះគប្បីតុលាការឱ្យជនជាប់ចោទ សងតាមសភាពជាក់ស្តែង និងសមហេតុផល តាមមាត្រា ១៤ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## សេចក្តីសម្រេច

១- កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] សំអឿន ពីបទៈ ប៉ុនប៉ងឃាតកម្ម តាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មកបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមមាត្រា ២១៨ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

២- ផ្តន្ទាទោស÷ ឈ្មោះ [redacted] សំអឿន ភេទប្រុស អាយុ៣៥ឆ្នាំ (កើតឆ្នាំ១៩៨៦) សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី)ឆ្នាំ។

ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិតាពេជ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

៣- វត្ថុតាង÷ កាំបិតប៉ុងតោចំនួន០២ដង និងដំបងឈើមូលពណ៌ក្រហមចំនួន០១ សម្រេចរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៤- បង្គាប់ឱ្យឈ្មោះ [redacted] សំអឿន សងសំណងជម្ងឺចិត្តចំនួន ៦,០០០,០០០ (ប្រាំមួយលាន)រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាវ៉ុម។ បណ្តឹងទាមទារលើសពីនេះច្រានចោល តាមមាត្រា ១៤ និងមាត្រា ៣៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំអឿន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាវ៉ុម និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២។ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: |

[redacted]

---

បានឃើញ

កណ្ដាល ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៨កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្ដាល ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

ក្រឡាបញ្ជីសវនាការ

[redacted]



Scanned with CamScanner